YUNNAN DAILY PRESS GROUP 云南日报报业集团 No.189

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី27 លេខ7977 ថ្ងៃសុក្រ ទី12 ខែកក្កដា ឆ្នាំ2019

## វេទិកាឃ្លាំងគំនិតចិន-អាស៊ី ខាងត្បូង និងអាស៊ីអាគ្នេយ៍លើកទី៧ប្រារព្ធនៅក្រុងគុនមីង



ពិធីសម្ពោធស្លាក មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនៅ ប្រទេសបាគីស្ថាននៃវិទ្យាស្ថាន សិក្សាស្រាវជ្រាវអាស៊ីខាងត្បូង និងអាស៊ី អាគ្នេយ៍(គុនមីង) ប្រទេសចិន



អ្នកជំនាញការ អន្តរជាតិកំពុងស្តាប់យោបល់របស់ តំណាង ប្រទេសផ្សេងៗដោយយកចិត្ត ទុកដាក់

នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៩ វេទិកាឃ្លាំងគំនិតចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍លើកទី ៧ បានបើកសម្ពោធនៅក្រុងគុនមីង នៃខេត្តយូនណាន ។ គិតមកដល់ពេលនេះ វេទិកានេះបានរៀបចំ ៧ លើកហើយ ដែលបានទទួលសមិទ្ធផលកាន់តែច្រើន និងមានឥទ្ធិពលកាន់តែខ្លាំងលើឆាកអន្តរជាតិ ។ វេទិកានេះបានរួមចំណែកក្នុងការបង្កើនកិច្ចសន្ទនាផ្នែកស្មារតីរវាងប្រទេសចិន និងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ព្រមទាំងបានផ្តល់យោបល់សំខាន់ដល់ប្រទេសពាក់ព័ន្ធក្នុងការកំណត់គោលនយោបាយផ្សេងៗ ។ ពេលនេះ យើងខ្ញុំសូមធ្វើបទបង្ហាញជូនលោកអ្នកអំពីសមិទ្ធផល នៃវេទិកាឃ្លាំងគំនិតចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍លើកទី ៧ នេះ ដើម្បីរួមគ្នាដើរឆ្ពោះទៅកាន់អនាគតដ៏ភ្លឺស្វាង ។

នៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៩ វេទិកាឃ្លាំងគំនិតចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍លើកទី ៧ បានបើកសម្ពោធនៅក្រុងគុនមីងនៃខេត្តយូនណាន ។ សព្វថ្ងៃវេទិកានេះបានក្លាយទៅជាវេទិកាឃ្លាំងគំនិតរវាងប្រទេសចិន(ខេត្តយូនណាន) និងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដែលមានកម្រិតថ្នាក់ខ្ពស់ជាងគេ មានអ្នកចូលរួមច្រើនជាងគេមានប្រធានបទពិគ្រោះពិភាក្សាគ្នាច្រើនជាងគេ និងបានទទួលសមិទ្ធផលច្រើនបំផុត ។

វេទិកាលើកនេះបានរៀបចំឡើងក្រោមប្រធានបទ"តភ្ជាប់ក្រអៅបេះដូងនិងដៃជើងរួមជោគវាសនាជាមួយគ្នា : កសាងសហគមន៍រួមវាសនាចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍" ។ ប្រធានបទនេះបានបង្ហាញពីទស្សនៈរួម និងគំនិតឯកភាពអំពីការចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោកដែលមានលក្ខណៈបើកទូលាយ និងការជំរុញកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងប្រទេសចិន និងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។

ពិតមែនតែអ្នកចូលរួមវេទិកាលើកនេះមានចំនួនតិចជាងវេទិកាលើកមុនតែភ្ញៀវកិត្តិយសជាង២០០រូប ដែលមកពីប្រទេសចំនួន១៩ សុទ្ធតែជាអ្នកតំណាងដ៏ឆ្នើមនៃស្ថាប័នឃ្លាំងគំនិតរបស់ប្រទេសផ្សេងៗ ។ ជាពិសេសអ្នកជំនាញការដែលចូលរួមក្នុងវេទិកានេះសុទ្ធតែមានឈ្មោះល្បីល្បាញក្នុងការសិក្សាស្រាវជ្រាវ និងការប្រឹក្សាយោបល់នៅបណ្តាប្រទេសពាក់ព័ន្ធ ។ ក្រៅពីអ្នកជំនាញការដែលមកពីប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ វេទិកាលើកនេះក៏បានទាក់ទាញឱ្យអ្នកជំនាញការអូស្ត្រាលី នូវែលសេឡង់ និងអាល្លឺម៉ង់ចូលរួមផងដែរ ។

ពិធីសម្ពោធស្លាក នៃមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវនៅប្រទេសប៉ាគីស្ថាននៃវិទ្យាស្ថានសិក្សាស្រាវជ្រាវអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ (គុនមីង) ប្រទេសចិន បានត្រូវរៀបចំឡើងក្នុងឱកាសវេទិកានេះ ។ លោក Muhammad Mudassir Tipu អគ្គកុងស៊ុលប្រទេសប៉ាគីស្ថានប្រចាំនៅក្រុងឈេីទូ បានលើកឡើងថា នេះជាគម្រោង សហប្រតិបត្តិការដ៏សំខាន់មួយដែលនឹងអាចជំរុញការកសាងរបៀងសេដ្ឋកិច្ចចិន-ប៉ាគីស្ថាន ។

"សហគមន៍រួមវាសនាមនុស្សជាតិ""ខ្សែក្រវាត់មួយ និងផ្លូវមួយ" "ការតភ្ជាប់គ្នាទាំង៥ វិស័យ" "ការតភ្ជាប់ក្រអៅបេះដូងប្រជាជន" "របៀងសេដ្ឋកិច្ច" និង"ការកាត់បន្ថយភាពក្រីក្រ"ជាពាក្យគន្លឹះ ដែលតែងតែត្រូវលើកឡើងក្នុងឱកាសវេទិកានេះ ។ វេទិកានេះមានប្រធានបទសំខាន់ចំនួន ៥ គឺ "កិច្ចសហប្រតិបត្តិការអនុតំបន់អន្តរជាតិនិងការកសាងរបៀងសេដ្ឋកិច្ច""ការផ្លាស់ប្តូរវប្បធម៌និងការតភ្ជាប់ក្រអៅបេះដូងប្រជាជន""កិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និងតំបន់ជុំវិញមហាសមុទ្រឥណ្ឌា" "ការអភិវឌ្ឍដោយបើកទូលាយ និងការចែករំលែកគ្នាអំពីបទពិសោធន៍" និង"ការកសាងមជ្ឈមណ្ឌលនាំផ្លូវអភិវឌ្ឍន៍ប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍" ។ ប្រធានបទទាំងនេះមិនគ្រាន់តែបានគ្របដណ្តប់លើកិច្ចសហប្រតិបត្តិការអនុតំបន់ របៀងសេដ្ឋកិច្ច កិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម ការផ្លាស់ប្តូរវប្បធម៌ ការតភ្ជាប់ក្រអៅបេះដូងប្រជាជន និងបញ្ហាសំខាន់មួយចំនួនទៀតប៉ុណ្ណោះទេ ហើយបានបន្ថែមនូវប្រធានបទថ្មីមួយចំនួនធំ ដូចជា ការបើកទូលាយទៅវិញទៅមក ការកាត់បន្ថយភាពក្រីក្រ សន្តិសុខ ឆ្លងដែន កិច្ចសហប្រតិបត្តិការប្រព័ន្ធផ្សព្វផ្សាយការគ្រប់គ្រងធនធានទឹកបញ្ហាជនជាតិនិងសាសនា បច្ចេកទេស៥G និងប្រព័ន្ធ AI ជាដើម ។

គួរបញ្ជាក់ថា អ្នកជំនាញការ ១២៣ រូបបានថ្លែងបាឋកថាក្នុងវេទិកានេះ ហើយបានប្រគល់នូវលទ្ធផលសិក្សាស្រាវជ្រាវចំនួនជាង១០០ ដែលមានពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងប្រទេសចិន និងប្រទេសអាស៊ីខាងត្បូងអាស៊ីអាគ្នេយ៍ ។ លទ្ធផលសិក្សាស្រាវជ្រាវទាំងនោះបានផ្តល់ព័ត៌មានអំពីបញ្ហាប្រឈម និងតម្រូវការចាំបាច់នៃបណ្តាប្រទេសនានា ព្រមទាំង បានលើកឡើងពីគោលដៅរួម និងអនាគតនៃការធ្វើកិច្ចសហប្រតិបត្តិការ ។

លទ្ធផលសិក្សាស្រាវជ្រាវចំនួន១០ បានត្រូវជ្រើសរើសជាលទ្ធផលសិក្សាស្រាវជ្រាវឆ្នើម និងបានទទួលរង្វាន់ ។ គណៈកម្មការរៀបចំវេទិកានេះនឹងប្រមូលយកលទ្ធផលសិក្សាស្រាវជ្រាវផ្សេងៗ ដើម្បីចងក្រងជា"កម្រងលទ្ធផលសិក្សាស្រាវជ្រាវនៃវេទិកាឃ្លាំងគំនិតចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍លើកទី ៧"(ឈ្មោះបណ្តោះអាសន្ន) ហើយបោះពុម្ពផ្សាយជាសាធារណៈដើម្បីចែករំលែកគ្នាជាមួយមិត្តអ្នកអានកាន់តែច្រើន ៕

**ដោយ លី ហុងហ៊ឹង**

## ឃ្លាំងគំនិតជាកម្លាំងសំខាន់សម្រាប់ការកសាង " ខ្សែក្រវាត់មួយ និងផ្លូវមួយ"





ភ្ញៀវកិត្តិយស ដែលមកពីប្រទេសផ្សេងៗផ្លាស់ប្តូរទស្សនៈជាមួយគ្នា



អ្នកជំនាញការ អន្តរជាតិកំពុងថ្លែងបាឋកថា

ក្នុងពិធីបើកវេទិកាឃ្លាំងគំនិតចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍លើកទី ៧ លោក ហ៊ឺ ជួយុន ប្រធានបណ្ឌិត្យសភាខេត្តយូនណាន បានថ្លែងសុន្ទរកថាសំខាន់ដែលមានចំណងជើងថា ឃ្លាំងគំនិតជាកម្លាំងសំខាន់សម្រាប់ការកសាង"ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។ អាស្រ័យលើសមិទ្ធផលសំខាន់នៃវេទិកាកំពូលស្តីពីកិច្ចសហប្រតិបត្តិការ"ខ្សែក្រវាត់មួយ និងផ្លូវមួយ"លើកទី ២ លោកបានលើកឡើងនូវសំណើចំនួន ៤ ដែលបានទាក់ទាញក្រសែភ្នែក និងទទួលការចាប់អារម្មណ៍ពីសំណាក់អ្នកជំនាញការនៃបណ្តាប្រទេសនានា ។

១- រួមគ្នាបកស្រាយឱ្យបានច្បាស់ថា ការកសាង"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ជាវេទិកាអនុវត្តន៍ជាក់ស្តែងដ៏សំខាន់សម្រាប់ការកសាងសហគមន៍រួមវាសនាមនុស្សជាតិ ដើម្បីផ្តល់ការណែនាំដល់ការធ្វើកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងប្រទេសចិនជាមួយប្រទេសអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍។ លោកបានលើកឡើងថា យើងទាំងអស់គ្នាត្រូវមានចក្ខុវិស័យវែងឆ្ងាយ ហើយវាយតម្លៃចំពោះគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ"តាម ចក្ខុវិស័យនៃការរួមសុខទុក្ខជាមួយគ្នា ។ បញ្ហាមូលដ្ឋាននៃការសិក្សាស្រាវជ្រាវ"ខ្សែក្រវាត់មួយ និងផ្លូវមួយ"របស់ឃ្លាំងគំនិតប្រទេសផ្សេងៗគឺ "តើត្រូវវាយតម្លៃចំពោះខ្សែក្រវាត់មួយ និងផ្លូវមួយតាមរបៀងណា?"នេះក៏ជាមូលដ្ឋានគ្រឹះនៃការទទួលស្គាល់និងការសិក្សាស្រាវជ្រាវអំពី"ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។ ការអនុវត្តជាក់ស្តែងបានសបញ្ជាក់ថា គំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ"អាចផ្តល់ផលប្រយោជន៍ដល់បណ្តាប្រទេសនានាលើពិភពលោក និងអាចជំរុញការអភិវឌ្ឍរួមនៃបណ្តាប្រទេសនានា ។ គំនិតផ្តួចផ្តើមនេះមិនមែនជាល្បិចចាស់ដើម្បីទទួលជ័យជម្នះក្នុងការប្រកួតប្រជែងក្នុងតំបន់នោះទេ។ វាជាផ្លូវអភិវឌ្ឍន៍ថ្មីដើម្បីសម្រេចនូវការធ្វើកិច្ចសហប្រតិបត្តិការដោយឈ្នះ-ឈ្នះ ។

២- រួមគ្នាសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅអំពីបញ្ហាសំខាន់សម្រាប់ជំរុញឱ្យគំនិតផ្តួចផ្តើម"ខ្សែក្រវាត់មួយ និងផ្លូវមួយ"ត្រូវបានអនុវត្តន៍ដោយជោគជ័យនៅប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដើម្បីផ្តល់គំនិត និងគម្រោងសម្រាប់ការធ្វើកិច្ចសហប្រតិបត្តិការជាក់ស្តែងរវាងប្រទេសចិនជាមួយប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ លោកបានបញ្ជាក់ថា យើងទាំងអស់គ្នាត្រូវសិក្សាស្រាវជ្រាវយ៉ាងហ្មត់ចត់អំពីបញ្ហាសំខាន់ផ្សេងៗ ដែលមានពាក់ព័ន្ធនឹងការកសាង"ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។ ឧទាហរណ៍ "តើយើងត្រូវធ្វើដូចម្តេចដើម្បីជំរុញឱ្យប្រទេសចិន និងប្រទេសអាស៊ីខាងត្បូងអាស៊ីអាគ្នេយ៍សម្រេចនូវការអភិវឌ្ឍដោយមានគុណភាពខ្ពស់ក្នុងដំណើរនៃការកសាងខ្សែក្រវាត់មួយ និងផ្លូវមួយ?" "តើយើងត្រូវបង្កើតទំនាក់ទំនងភាពជាដៃគូតភ្ជាប់គ្នារវាងប្រទេសចិន និងប្រទេសអាស៊ីខាងត្បូង អាស៊ីអាគ្នេយ៍តាមរបៀបណា?" ជាដើម ដើម្បីផ្តល់សំណើ និងគម្រោងដ៏មានតម្លៃដល់ការធ្វើកិច្ចសហប្រតិបត្តិការរវាងប្រទេសចិន និងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។

ទី៣ -រួមគ្នាសិក្សាស្រាវជ្រាវយ៉ាងស៊ីជម្រៅអំពីការបង្កើតយន្តការសហប្រតិបត្តិការ និងជំរុញការអភិវឌ្ឍនៃវេទិកា ដើម្បីកំណត់ស្តង់ដារសម្រាប់ការកសាងសហគមន៍រួមវាសនាចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ។ ឧទាហរណ៍ឈរលើមូលដ្ឋាននៃវិស័យសហប្រតិបត្តិការសំខាន់ៗរវាងប្រទេសចិននិងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ជំរុញការទទួលស្គាល់គ្នាអំពីស្តង់ដារនៃបណ្តាប្រទេសពាក់ព័ន្ធលើវិស័យផ្សេងៗ ។ ក្រៅពីនេះ ភាគីនានាត្រូវចាត់ទុកតំបន់សហប្រតិបត្តិការសេដ្ឋកិច្ចឆ្លងដែន និងគម្រោងសហប្រតិបត្តិការអន្តរជាតិជាចំណុចស្នូលជំរុញការទទួលស្គាល់គ្នាអំពីស្តង់ដារដែលមានស្រេចនិងការកំណត់ស្តង់ដារថ្មីដើម្បីជំរុញឱ្យប្រទេសចិន និងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍រួមគ្នាបង្កើតប្រព័ន្ធស្តង់ដាររួមសម្រាប់ការកសាង"ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។

ទី៤- រួមគ្នាពិគ្រោះពិភាក្សាយ៉ាងស៊ីជម្រៅអំពីមធ្យោបាយសម្រាប់ជំរុញការតភ្ជាប់ក្រអៅបេះដូងប្រជាជនដើម្បីកសាងមូលដ្ឋានគ្រឹះផ្នែកប្រជាមតិសម្រាប់ការកសាងសហគមន៍រួមវាសនាចិន-អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ។ យើងត្រូវពិគ្រោះពិភាក្សាគ្នាយ៉ាងស៊ីជម្រៅអំពីវិធីជំរុញការតភ្ជាប់ក្រអៅបេះដូងប្រជាជន ខិតខំកសាងស្ពានសំខាន់សម្រាប់ការផ្លាស់ប្តូររវាងអរិយធម៌ផ្សេងៗ បង្កើនកិច្ចសហប្រតិបត្តិការលើវិស័យឃ្លាំងគំនិតប្រព័ន្ធផ្សព្វផ្សាយ អប់រំ វប្បធម៌ បច្ចេកវិជ្ជា កីឡា ទេសចរណ៍ និងសុខាភិបាលជា ដើម ខិតខំបំបាត់ការខ្វែងគ្នាដែល បណ្តាលមកពីការច្រឡំគ្នាដើម្បីសរសេរឱ្យបានកាន់តែល្អប្រសើរនូវ"រឿងអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍តាមផ្លូវ សូត្រ"៕

**ដោយ លី ហុងហ៊ឹង**